00285352

C22/5/26



**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៧)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ៤ មិនា ២០០៩

ប្រធាន **ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / MAR / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

---

សាធារណៈ:

## សេចក្តីបង្គាប់ដល់ភាគី ទាក់ទងនឹងសំណើជាបន្ទាន់របស់ អៀង សារី សុំសេចក្តីបង្គាប់មួយ ឲ្យមន្ទីរពេទ្យកាល់ម៉ែត្រ បង្ហាញចេញជាប្រញាប់នូវកំណត់ត្រាវេជ្ជសាស្ត្រនានា និងបញ្ជីឈ្មោះគ្រូពេទ្យដែលព្យាបាល លោក អៀង សារី

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
គាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR
Elizabeth RABESANRATANA
Olivier BAHOUGNE
David BLACKMAN

**សហមេធាវីការពារក្តី**

អាង ឧត្តម
Michael G. KARNAVAS

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / MAR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") កត់សម្គាល់ឃើញ "សំណើជាបន្ទាន់របស់លោក **អៀង សារី** សុំសេចក្តីមួយឱ្យមន្ទីរពេទ្យកាល់ម៉ែត្រ បង្ហាញចេញជាប្រញាប់នូវកំណត់ត្រាវេជ្ជសាស្ត្រនានា និងបញ្ជីឈ្មោះគ្រូពេទ្យដែលព្យាបាលលោក **អៀង សារី**"។ សំណើនេះ បានដាក់ នៅថ្ងៃទី៣ ខែមិនា ឆ្នាំ២០០៩ ដោយសហមេធាវីជនត្រូវចោទ ("សំណើ")។

១. នៅក្នុងសំណើរបស់ខ្លួន, សហមេធាវីការពារក្តី ស្នើសុំឱ្យអង្គបុរេជំនុំជម្រះបង្គាប់ឱ្យមន្ទីរពេទ្យកាល់ម៉ែត្រ:

១) បង្ហាញចេញជាបន្ទាន់នូវរាល់របាយការណ៍វេជ្ជសាស្ត្រទាំងអស់ ដែលទាក់ទងនឹងលោក **អៀង សារី** បន្ទាប់ពីគាត់ត្រូវបានសំរាកព្យាបាលនៅមន្ទីរពេទ្យជាបន្តបន្ទាប់។

២) ផ្តល់បញ្ជីរាយនាមបណ្តាគ្រូពេទ្យទាំងអស់ដែលបានព្យាបាលលោក **អៀង សារី** នៅក្នុងអំឡុងពេលដែលគាត់បានសំរាកព្យាបាលនៅមន្ទីរពេទ្យ រួមទាំងព័ត៌មានស្តីពីមុខងាររបស់គ្រូពេទ្យម្នាក់ៗក្នុងការព្យាបាលលោក **អៀង សារី** ។ និង,

៣) ផ្តល់នូវព័ត៌មានអំពីសមាជិកនានា រចនាសម្ព័ន្ធ និងអំណាចរបស់ *"គណៈកម្មាធិការ"* ដែលទំនងជាធ្វើការសម្រេចសេចក្តីសំខាន់ៗនានា ចំពោះការព្យាបាលដល់លោក **អៀង សារី** ។

២. អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសមស្រប ដែលត្រូវកំណត់កាលបរិច្ឆេទឱ្យភាគីនៅក្នុងសំណុំរឿងលេខ **០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៧)** ដាក់សេចក្តីសន្និដ្ឋានតបចំពោះពាក្យសុំនេះ ជាប្រញាប់។

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះបង្គាប់:**

**ភាគី** ត្រូវដាក់សេចក្តីសន្និដ្ឋានតបចំពោះសំណើនេះ ត្រឹមថ្ងៃ **ពុធ ទី១១ ខែមិនា ឆ្នាំ២០០៩** វេលាម៉ោង **១៦:០០ រសៀល**។

ភ្នំពេញ ថ្ងៃទី៤ ខែមិនា ឆ្នាំ២០០៩

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER

**ប្រាក់ គឹមសាន**